**ប្រការ ៤** : រោងចក្រនេះ ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល«ចារី» ទៅតាមគំរូ និង ផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៥** : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ ល្មើសប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះ និង ត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ពូ សុធីរៈ**

* * *

# ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សារាចរ

ភ្នំពេញ , ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៨៦

**សារាចរលេខ : ០០២ ស.រ.**

**អនុវត្តច្បាប់ ស្តីពីការបង្ក្រាបល្បែងស៊ីសង**

ដើម្បីធានាការអនុវត្តន៍ច្បាប់ ស្តីពីការបង្ក្រាបល្បែងបស៊ីសងដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស.រកម.០១៨៦.២៨ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៨៦ អោយមាន ប្រសិទ្ធភាពក្រសួងសូមណែនាំនូវវិធានការដូចខាងក្រោមនេះ ÷

១–អភិបាលខេត្ត ក្រុង និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និង ក្រុងកែប ក្នុងតួនាទីជាប្រធានគណៈបញ្ជាការឯកភាពខេត្ត ក្រុង ត្រូវមានវិធានការម៉ឺងម៉ាត់ ដល់មន្ត្រីរាជការ ស៊ីវិលនគរបាលជាតិ ក៏ដូចជាប្រជាពលរដ្ឋទាំងអស់ ដែលស្ថិតនៅក្រោមនិវាទ និង កំពុងរស់នៅ ក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនអោយអនុវត្តច្បាប់ ស្តីពីការបង្ក្រាបល្បែងស៊ីសងដោយហាមមិនអោយ មន្ត្រីរាជការស៊ីវិលនគរបាលជាតិ កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង ប្រជាពលរដ្ឋ ទាំងអស់លេងល្បែងស៊ីសង ឬការពារ ឬបើកបទល្បែងស៊ីសងជាដាច់ខាត ។

អ្នកប្រព្រឹត្តបទល្មើស ត្រូវចាប់បញ្ជូនខ្លួនទៅតុលាការ ។

២–អំពីសមត្ថកិច្ចក្នុងការបង្ក្រាបល្បែងស៊ីសង :

ការបង្រ្កាបល្បែងស៊ីសងជាសមត្ថកិច្ចរបស់មន្ត្រី ដូចខាងក្រោម ÷

–អភិបាល អភិបាលរងខេត្ត ក្រុង ស្រុក ខណ្ឌ ។

–អគ្គនាយក អគ្គនាយករងនគរបាលជាតិ ។

–ប្រធាន អនុប្រធាន នាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ ។

–ប្រធាន អនុប្រធាន នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ។

–ស្នងការ ស្នងការរង ។

–ប្រធានការិយាល័យនគរបាលព្រហ្មទណ្ឌ កិរិតស្រាល ។

–អធិការ អធិការរង ។

–ប្រធានប៉ុស្តិ៍ នគរបាលរដ្ឋបាល ។

ដោយឡែកការរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

៣–អំពីនីតិវិធី នៃការរឹបអូសប្រាក់ក្នុងវង់ល្បែង និង វត្ថុតាង :

ក្នុងករណីណាក៏ដោយ ប្រាក់ដាក់ក្នុងវង់ល្បែង ប្រាក់មាននៅនឹងខ្លួនអ្នកចាត់ចែងល្បែង នៅនឹងខ្លួនមេល្បែង នៅនឹងខ្លួនភ្នាក់ងារល្បែង នៅនឹងខ្លួនអ្នកជួយស៊ីសងក្នុងវង់ល្បែង នៅនឹងខ្លួនអ្នកទទួលភារកិច្ចខាងគណនេយ្យ នៅនឹងខ្លួនអន្តរការី និង នៅនឹងខ្លួនអ្នកលេងល្បែង ត្រូវមន្ត្រីមានសមត្ថកិច្ច ដូចបានរៀបរាប់ខាងលើចាប់រឹបអូស ហើយធ្វើកំណត់ហេតុអោយបានត្រឹមត្រូវបញ្ជូនទៅតុលាការ ។

ចំណែកវត្ថុតាងសំរាប់បំរើអោយការលេងល្បែងនោះក៏ត្រូវរឹបអូសដូចប្រាក់ដែរ ។

ការផលិត ការនាំចូលដើម្បីធ្វើអាជីវកម្ម ការលក់ឧបករណ៍ល្បែងស៊ីសងគ្រប់ ប្រភេទដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល ត្រូវផ្តន្ទាទោសតាមមាត្រា ៨ នៃច្បាប់ ស្តីពីការបង្រ្កាបល្បែងស៊ីសង ។ ឧបករណ៍នៃវត្ថុតាងនេះ ក៏មន្ត្រីមានសមត្ថកិច្ច ត្រូវរឹបអូសដែរ ។

ប្រាក់ និង វត្ថុតាងទាំងអស់ដែលរឹបអូសបានដូចខាងលើ មន្ត្រីមានសមត្ថកិច្ច ត្រូវតែបញ្ជូនជាមួយនឹងសំណុំរឿងទៅតុលាការ ដើម្បីសំរេចរឹបអូស ឬបំផ្លាញចោល ។

ចំពោះប្រាក់រង្វាន់សំរាប់មន្ត្រីមានសមត្ថកិច្ច អង្គភាព និង ជនដែលបានចូលរួមកិច្ចប្រតិបត្តិការនេះ និង មានកំណត់ដោយឡែកក្នុងអនុក្រឹត្យ ។

៤–អំពីប្រភេទ នៃល្បែងស៊ីសងដែលត្រូវបង្រ្កាប :

–ល្បែងបៀគ្រប់ប្រភេទ ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ល្បែងឡូតូ ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ឆ្នោតគ្រប់រូបភាព ដែលស៊ីសងជាប្រាក់ រួមទាំងកន្ទុយលេខផង

-ឆ្នោតវត្ថុគ្រប់ប្រភេទ

-ល្បែងអាប៉ោង ផ្ល ឡុកឡាក់ យុតី និង ខ្លាឃ្លោក ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់ ។

-ល្បែងជល់សត្វ ឬ ប្រណាំងសត្វគ្រប់ប្រភេទស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាចប្រាក់ ។

-ល្បែងទឹកភ្លៀងគ្រប់រូបភាព ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ល្បែងរូលឡែត គ្រប់រូបភាព ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ល្បែងវីដេអូហ្គេមគ្រប់ប្រភេទ ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ព្រមទាំងល្បែងស៊ីសងទាំងឡាយដទៃទៀត ។

ល្បែងស៊ីសងទាំងអស់ខាងលើនេះអាចលេងបាន បើមានការអនុញ្ញាតច្បាប់ពីរាជរដ្ឋាភិបាល ក្នុងករណីគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល មន្ត្រីមានសមត្ថកិច្ចបង្ក្រាបល្បែងស៊ីសងដូចមានចែង ក្នុងចំណុចទី ២ នៃសារាចរនេះ ត្រូវចាត់វិធានការបង្ក្រាបជាបន្ទាន់ ។

ក្រសួងប្រគល់ភារកិច្ចអោយអគ្គនាយកនគរបាលជាតិ ធ្វើជាសេនាធិការដើម្បីចង្អុលណែនាំ លើកទិស និង ដឹកនាំអនុវត្តការងារនេះ ។

សារាចរនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា និង ត្រា

**ស ខេង យូ ហុកគ្រី**

* * *